ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ៦០៧ គ.ជ.ប

សេចក្តីណែនាំ
ស្តីពី
ការលើកស្លាកសញ្ញាគណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ។

ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ អនុវត្តឱ្យបានត្រឹមត្រូវ ឈរលើគោលការណ៍ស្មើភាព និងលំដាប់មុនក្រោយ ក្នុងការលើកស្លាកសញ្ញាគណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំដល់គណបក្សនយោបាយ អាជ្ញាធរដែនដី និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដូចខាងក្រោម ៖

១. ការលើកស្លាកសញ្ញាគណបក្សនយោបាយ ក្នុងពេលឃោសនាបោះឆ្នោត

ការលើកស្លាកគណបក្សនយោបាយមាន ៣ ប្រភេទ ៖

១.១ ការលើកស្លាកសញ្ញាគណបក្សនយោបាយនៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

១.២ ការលើកស្លាកសញ្ញាគណបក្សនយោបាយនៅទីលំនៅឋានឯកជន ឬទីកន្លែងឯកជន ។

១.៣ ការលើកស្លាកសញ្ញាគណបក្សនយោបាយនៅទីកន្លែងសាធារណៈ ។

២. ការលើកស្លាកសញ្ញាគណបក្សនយោបាយ នៅទីសាធារណៈ និងទីកន្លែងឯកជន

- ការលើកស្លាកសញ្ញាគណបក្សនយោបាយនៅទីកន្លែងសាធារណៈ ក្នុងអំឡុងពេលយោសនាបោះឆ្នោត ត្រូវមានការសម្របសម្រួលជាមួយអាជ្ញាធរដែនដី ដោយឈរលើគោលការណ៍ស្មើភាពលំដាប់មុន ក្រោយ ។
- ការលើកស្លាកសញ្ញាគណបក្សនយោបាយនៅលំនៅឋានឯកជន ឬទីកន្លែងឯកជន ត្រូវមានការយល់ព្រមពីម្ចាស់កន្លែងនោះ ។

៣. ស្លាកសញ្ញាគណបក្សនយោបាយ និងការិយាល័យបោះឆ្នោត

- ស្លាកសញ្ញាគណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការយោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ដែលត្រូវគ្រប ឬបិទបាំង។
- គណបក្សនយោបាយ ត្រូវប្រមូលមកវិញទាំងអស់ពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត នូវស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារយោសនាបោះឆ្នោត ដែលបានលើក ឬបិទនៅទីសាធារណៈក្នុងអំឡុងពេលយោសនាបោះឆ្នោត ។

៤. ការអនុវត្ត

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) អាជ្ញាធរដែនដី និងគណបក្សនយោបាយ ត្រូវសហការគ្នាដើម្បីឱ្យការយោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ប្រព្រឹត្តទៅដោយសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រី ប្រធាន គធ.ខប និង គឃ.សប អាជ្ញាធរដែនដី គណបក្សនយោបាយទាំងអស់ យកចិត្តទុកដាក់អនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៧

ជ. ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ស៊ុក ប៊ុនហុក

ចម្លងជូន

- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- គណបក្សនយោបាយ ចូលរួមការបោះជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧
  "ដើម្បីអនុវត្ត"
- គធ.ខប ទាំង ២៥
- សាលារាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ